**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥០ និងកិច្ចប្រជុំពាក់ព័ន្ធ
# ថ្ងៃទី ០៤ ដល់ ០៨ ខែសីហា ឆ្នាំ២០១៧
# ទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន

---------

ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូចូលរួមកិច្ចប្រជុំដូចខាងក្រោម នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥០ និងកិច្ចប្រជុំពាក់ព័ន្ធ ដែលបានប្រព្រឹត្តទៅក្រោមមូលបទ "រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្តូរ រួមចំណែកជាមួយពិភពលោក" ពីថ្ងៃទី០៤ ដល់ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ នៅទីក្រុងម៉ានីល សាធារណរដ្ឋហ្វីលីពីន។

## I. <u>កិច្ចប្រជុំគណៈកម្មការតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ</u> (ថ្ងៃទី ០៤/០៨/១៧)

កិច្ចប្រជុំបានពិនិត្យឡើងវិញអំពីវឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាពរបស់សន្ធិសញ្ញាតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (២០១៣-២០១៧) និងបានឯកភាពពន្យាផែនការសកម្មភាពនេះសម្រាប់ឆ្នាំ២០១៨-២០២២។ កិច្ចប្រជុំក៏បានអះអាងឡើងវិញពីការតាំងចិត្តដោះស្រាយរាល់បញ្ហាលេចធ្លោរពាក់ព័ន្ធដល់ការចុះហត្ថលេខារបស់រដ្ឋអាវុធនុយក្លេអ៊ែរលើពិធីសារនៃសន្ធិសញ្ញាតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ។

ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន បានគូសបញ្ជាក់ពីការគាំទ្រយ៉ាងខ្លាំងក្លារបស់កម្ពុជាចំពោះការរក្សាតំបន់អាស៊ីអាគ្នេយ៍ជាតំបន់គ្មានអាវុធនុយក្លេអ៊ែរ និងបានកត់សម្គាល់អំពីការវិវឌ្ឍយឺតយ៉ាវនៃការពិគ្រោះយោបល់រវាងអាស៊ាន និងរដ្ឋអាវុធនុយក្លេអ៊ែរ។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានស្នើដល់ប្រទេសសមាជិកអាស៊ានធ្វើការសម្របសម្រួលជំហររួមលើឧបមុងរបស់រដ្ឋអាវុធនុយក្លេអ៊ែរ មុននឹងចាប់ផ្តើមការពិភាក្សាឡើងវិញជាមួយប្រទេសទាំងនោះ និងបានអះអាងថា កម្ពុជាអាចគាំទ្របំណង និងការត្រៀមខ្លួនរួចរាល់របស់ចិន ជារដ្ឋអាវុធនុយក្លេអ៊ែរទី១ ដើម្បីចុះហត្ថលេខា និងផ្តល់សច្ចាប័នលើពិធីសារនៃសន្ធិសញ្ញាតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធ



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

នុយក្លេអ៊ែរដោយមិនមានឧបម្រុង ដើម្បីផ្តល់ជាសញ្ញាវិជ្ជមានខ្ពស់ដល់រដ្ឋអាវុធនុយក្លេអ៊ែរផ្សេងទៀត ធ្វើការពិចារណាលើជំហររបស់គេក្នុងការដកចេញនូវឧបម្រុងនានា។

## II. ជំនួបរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយតំណាងគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស

កិច្ចប្រជុំបានពិនិត្យលើវឌ្ឍនភាពការងាររបស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស និងការអនុវត្តនៃសេចក្តីថ្លែងការណ៍អាស៊ានស្តីពីសិទ្ធិមនុស្ស និងសេចក្តីប្រកាសទីក្រុងភ្នំពេញស្តីពីការអនុម័តសេចក្តីថ្លែងការណ៍អាស៊ានស្តីពីសិទ្ធិមនុស្ស។ កិច្ចប្រជុំបានធ្វើការកត់សម្គាល់លើរបាយការណ៍ប្រចាំឆ្នាំ២០១៧ របស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស និងបានអនុម័តកម្មវិធី/សកម្មភាពអាទិភាពរបស់គណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស ឆ្នាំ២០១៨។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានអបអរដល់សមិទ្ធផលដែលបានលើកឡើងនៅក្នុងសុន្ទរកថារបស់ប្រធានគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ានស្តីពីសិទ្ធិមនុស្ស ជាពិសេសសមិទ្ធផលពាក់ព័ន្ធនឹងការអនុវត្តសេចក្តីថ្លែងការណ៍អាស៊ានស្តីពីសិទ្ធិមនុស្ស ហើយឯកឧត្តមទេសរដ្ឋមន្ត្រីបានសង្កត់ធ្ងន់លើការសម្រេចនូវផែនការសកម្មភាពតំបន់ដើម្បីបញ្ជ្រៀបសិទ្ធិជនពិការក្នុងសហគមន៍អាស៊ាន។

## III. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥០

ក្រោមមូលបទ "រួមគ្នាជាដៃគូដើម្បីធ្វើការផ្លាស់ប្តូរ រួមចំណែកជាមួយពិភពលោក" រដ្ឋមន្ត្រីការបរទេសអាស៊ានបានផ្តោតការពិភាក្សាលើការកសាងសហគមន៍អាស៊ាន និម្មាបនកម្មតំបន់ និងទំនាក់ទំនងខាងក្រៅជាមួយដៃគូអាស៊ាន ព្រមទាំងផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់ និងបញ្ហាអន្តរជាតិ រួមមាន បញ្ហាឧបទ្វីបកូរ៉េ សមុទ្រចិនខាងត្បូង ការប្រយុទ្ធប្រឆាំងអំពើហិង្សាជ្រុលនិយម រ៉ាឌីកាល់និយម និងភេរវកម្ម និងស្ថានភាពនៅមជ្ឈិមបូព៌ា។

រដ្ឋមន្ត្រីការបរទេសអាស៊ានបានលើកសរសើរដល់ការងាររបស់ផ្នែកជំនាញតាមវិស័យ និងអង្គភាពរបស់អាស៊ាន ក្នុងការអនុវត្តយ៉ាងពេញលេញ និងមានប្រសិទ្ធភាព នូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ ផែនការលម្អិតទាំងបីនៃសហគមន៍នយោបាយ-សន្តិសុខអាស៊ាន សហគមន៍សេដ្ឋកិច្ចអាស៊ាន និងសហគមន៍សង្គម-វប្បធម៌អាស៊ាន ផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ និងផែនការការងារដំណាក់កាលទី៣នៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន។

នៅក្នុងបទអន្តរាគមន៍ ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការរក្សាឲ្យបាននូវការធ្វើសមាហរណកម្មអាស៊ាន និងការកសាងសហគមន៍ តាមរយៈការលើកកម្ពស់ការកសាងសមត្ថភាព នៅកម្ពុជា ឡាវ មីយ៉ាន់មា និងវៀតណាម និងកៀរគរធនធានបន្ថែម ដើម្បីអនុវត្តផែនការការងារដំណាក់កាលទី៣នៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន និងផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ ដើម្បីជម្នះនូវភាពអវិជ្ជមាន ដែលកើតចេញពីការងើបឡើងនៃចលនាប្រជានិយម បដិសាកលភាវូបនីយកម្ម ការប្រឆាំងសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការគាំពារនិយម នៅលើពិភពលោក។ ឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានសង្កត់ធ្ងន់លើភាពចាំបាច់នៃកិច្ចប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការរួមក្នុងការប្រឆាំងការកើនឡើងនៃការគំរាមគំហែង

មិនប្រពៃណី រាប់ចាប់ពីការជួញដូរមនុស្ស គ្រឿងញៀន រហូតដល់ឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ីនធឺណែត និងភេរវកម្ម ដើម្បីផ្តល់នូវបរិកាសប្រកបដោយសុវត្ថិភាព និងសន្តិសុខ សម្រាប់សហគមន៍អាស៊ាន។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានបញ្ជាក់ជាថ្មីថា កម្ពុជាចូលរួមរក្សាតួនាទីស្នូល សាមគ្គីភាព និងឯកភាពរបស់អាស៊ាន ក្នុងគោលដៅរក្សាតំបន់អាស៊ានឲ្យមានសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាព។ ក្នុងខណៈពេលដែលយើងកំពុងប្រឈមនឹងការងើបឡើងនៃការប្រកួតប្រជែងរបស់មហាអំណាច អាស៊ានក៏បានទទួលរងផលប៉ះពាល់ពីស្ថានភាពនៃប្រកួតប្រជែងនេះ ដើម្បីកំណត់នូវរបៀបវារៈសម្រាប់តំបន់។ ប្រការនេះអាចប៉ះពាល់ដល់តួនាទីស្នូលរបស់អាស៊ាន និងអាចបំបែកអាស៊ានតាមរយៈនៃការទាញយកប្រយោជន៍សម្រាប់ប្រទេសរៀងៗខ្លួន។

រដ្ឋមន្ត្រីការបរទេសអាស៊ានបានឯកភាពផ្តល់ឋានៈដល់ប្រទេសទួរគីជាដៃគូសន្ទនា តាមវិស័យរបស់អាស៊ាន។ កិច្ចប្រជុំក៏បានឯកភាពបន្តការពិភាក្សាលើសំណើរបស់ទីម័រខាងកើតជាសមាជិករបស់អាស៊ាន និងដើម្បីជួយពង្រឹងសមត្ថភាព កិច្ចប្រជុំក៏បានស្វាគមន៍ទីម័រខាងកើតចូលរួមក្នុងសកម្មភាពនានារបស់អាស៊ាន។

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥០ បានអនុម័ត និងចេញផ្សាយ៖

១.សេចក្តីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥០

២.សេចក្តីថ្លែងការណ៍រួមរបស់ថ្នាក់ដឹកនាំអាស៊ានសម្រាប់ខួបអាស៊ានលើកទី៥០

៣.សេចក្តីប្រកាសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានស្តីពីការវិវឌ្ឍន៍នៅឧបទ្វីបកូរ៉េ និង

៤.សេចក្តីប្រសកាសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ានស្តីពីស្ថានការណ៍នៅបរិវេណ Al-Haram Al-Sharif។

## IV. <u>សន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយរដ្ឋមន្ត្រីការបរទេសដៃគូសន្ទនា</u>

របៀបវារៈនៃសន្និសីទក្រោយកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយបណ្តាប្រទេសដៃគូសន្ទនាអាស៊ានរួមមានជាមួយអូស្ត្រាលី កាណាដា ចិន សហភាពអឺរ៉ុប ជប៉ុន នូវែលហ្សេឡង់ សាធារណរដ្ឋកូរ៉េ រុស្ស៊ី និងសហរដ្ឋអាមេរិក ផ្តោតជាសំខាន់លើការពិនិត្យឡើងវិញនិងការកំណត់ទិសដៅអនាគតនៃទំនាក់ទំនងដៃគូអាស៊ានជាមួយបណ្តាដៃគូសន្ទនាអាស៊ាននីមួយៗ ព្រមទាំងបានផ្លាស់ប្តូរយោបល់ស្តីពីបញ្ហាតំបន់ និងអន្តរជាតិ។

រដ្ឋមន្ត្រីបានបញ្ជាក់អំពីការប្តេជ្ញាចិត្ត ដើម្បីគាំពារ និងពង្រឹងសន្តិភាព សន្តិសុខ និងស្ថិរភាព នៅក្នុងតំបន់ ពង្រីកទំនាក់ទំនងដែលជាប្រយោជន៍សម្រាប់គ្នាទៅវិញទៅមករវាងអាស៊ាននិងប្រទេសដៃគូសន្ទនា ព្រមទាំងការគាំទ្រនូវតួនាទីស្នូល និងតួនាទីសកម្មរបស់អាស៊ាននៅក្នុងនិម្មាបនកម្មតំបន់។

<u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយសាធារណរដ្ឋកូរ៉េ</u> ដែលឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន បានដឹកនាំធ្វើជាសហប្រធាន ជាមួយ**លោកជំទាវ កាង យ៉ុងវ៉ា** រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ បានអះអាងឡើងវិញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំ អំពីការប្រើប្រាស់ឲ្យពេញលេញនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-សាធារណរដ្ឋកូរ៉េ ជាមធ្យោបាយសម្រេចឲ្យបាននូវទំហំពាណិជ្ជកម្មទៅវិញទៅមកចំនួន ២០០ពាន់លានដុល្លារអាមេរិក នៅឆ្នាំ២០២០។ កិច្ចប្រជុំនេះក៏បានលើកទឹកចិត្តថែមទៀតដល់ការគាំទ្ររបស់សាធារណរដ្ឋកូរ៉េ ដើម្បីអនុវត្តផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ និងផែនការដំណាក់កាលទី៣នៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន។ កិច្ចប្រជុំទន្ទឹងរង់ចាំពិធីបើកសម្ពោធផ្ទះវប្បធម៌អាស៊ាន នៅទីក្រុងប៊ូសាន ថ្ងៃទី១ ខែកញ្ញា

ឆ្នាំ២០១៧ និងបានឯកភាពរៀបចំសកម្មភាពដែលមានអត្ថន័យជាច្រើន ដើម្បីប្រារព្ធឆ្នាំផ្លាស់ប្តូរវប្បធម៌អាស៊ាន-កូរ៉េ ក្នុងឆ្នាំ២០១៧នេះ។ កិច្ចប្រជុំបានសង្កត់ធ្ងន់អំពីសារសំខាន់នៃការផ្តល់អាទិភាពសម្រាប់ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងវិនិយោគ ដោយផ្តោតលើវិស័យសហគ្រាសមីក្រូ-តូចនិងមធ្យម និងទេសចរណ៍។

**កិច្ចប្រជុំជាមួយអូស្ត្រាលី៖** ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន បានបង្ហាញនូវក្តីសង្ឃឹមថា អាហារូបករណ៍ជាច្រើនថែមទៀតនឹងត្រូវបានផ្តល់ជាអាទិភាពដល់ប្រទេសកម្ពុជា-វៀតណាម ឡាវ និងមីយ៉ាន់ម៉ា ដើម្បីធ្វើឲ្យប្រសើរឡើងនូវការអភិវឌ្ឍធនធានមនុស្ស ដែលអាចឲ្យប្រទេសទាំងនោះរួមចំណែកដល់ការកសាងសហគមន៍អាស៊ាន។ ក្នុងកិច្ចប្រជុំនេះ រដ្ឋមន្ត្រីការបរទេសអូស្ត្រាលីបានជម្រាបជូនអំពីការត្រៀមរៀបចំកិច្ចប្រជុំកំពូលពិសេសអាស៊ាន-អូស្ត្រាលី នៅខែមីនា ឆ្នាំ២០១៨។ រដ្ឋមន្ត្រីបានរំពឹងថា កិច្ចប្រជុំកំពូលពិសេសរវាងថ្នាក់ដឹកនាំនៃប្រទេសសមាជិកអាស៊ាននិងអូស្ត្រាលី នឹងពង្រឹងបាននូវទំនាក់ទំនងដៃគូសន្ទនាជាយុទ្ធសាស្ត្រអាស៊ាន-អូស្ត្រាលីមួយកម្រិតបន្ថែមទៀត។

**នៅក្នុងកិច្ចប្រជុំជាមួយកាណាដា** រដ្ឋមន្ត្រីការបរទេសអាស៊ានបានស្វាគមន៍ចំពោះគម្រោងថ្មីរបស់ កាណាដា ស្តីពីកម្មវិធីអាហារូបករណ៍ និងការផ្លាស់ប្តូរវិស័យអប់រំ សម្រាប់ការអភិវឌ្ឍ ដែលមានទឹកប្រាក់ចំនួន ១០ លានដុល្លារអាមេរិក ដើម្បីគាំទ្រដល់យុវជន និងអ្នកជំនាញអាជីពកម្រិតកណ្តាល ជាពិសេសស្ត្រី និងសម្រាប់ប្រទេសកម្ពុជា-ឡាវ-មីយ៉ាន់ម៉ារ-និងវៀតណាម ដើម្បីសិក្សារយៈពេលខ្លីនៅប្រទេសកាណាដា ដែលនឹងជួយដល់ពួកគាត់ក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់អាស៊ាន។

**នៅក្នុងកិច្ចប្រជុំជាមួយចិន៖** ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន បានវាយតម្លៃខ្ពស់អំពីការចូលរួមចំណែករបស់ចិនក្នុងដំណើរការសមាហរណកម្មអាស៊ាន និងការកសាងសហគមន៍អាស៊ាន រួមទាំងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងវិថី ព្រមទាំងបានប្រកាសអំពីគម្រោងរបស់កម្ពុជាក្នុងការរៀបចំកម្មវិធីផ្លាស់ប្តូរយុវជនអាស៊ាន-ចិន លើកទី៣ ដើម្បីជំរុញការតភ្ជាប់ប្រជាជននិងប្រជាជន និងដើម្បីពង្រឹងបន្ថែមទៀតនូវចំណងមិត្តភាពរវាងប្រជាជននៃបណ្តាប្រទេសសមាជិកអាស៊ាន និងចិន។ កិច្ចប្រជុំបានអនុម័តនូវក្របខ័ណ្ឌការងារនៃក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង និងបានប្រគល់ភារកិច្ចដល់មន្ត្រីជាន់ខ្ពស់ក្នុងការចាប់ផ្តើមការពិគ្រោះយោបល់ និងការចរចាស្តីពីក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូងប្រកបដោយខ្លឹមសារ។ រដ្ឋមន្ត្រីក៏បានអនុម័តលើសេចក្តីថ្លែងការណ៍របស់ថ្នាក់ដឹកនាំអាស៊ាននិងចិនស្តីពីមួយទសវត្សរ៍នៃការការពារតំបន់ឆ្នេរនិងបរិស្ថានលំហសមុទ្រ នៅក្នុងសមុទ្រចិនខាងត្បូង (២០១៧-២០២៧) និងបានចុះហត្ថលេខាលើការកែសម្រួលអនុស្សារណៈស្តីពីការបង្កើតមជ្ឈមណ្ឌលអាស៊ាន-ចិន។ កិច្ចប្រជុំក៏បានឯកភាពផ្តើមធ្វើសេចក្តីប្រកាសរួមស្តីពីកិច្ចសហប្រតិបត្តិការទេសចរណ៍ ដែលគ្រោងចេញផ្សាយនៅក្នុងកិច្ចប្រជុំកំពូលអាស៊ាន-ចិន លើកទី២០ នាខែវិច្ឆិកា ឆ្នាំ២០១៧។

**កិច្ចប្រជុំជាមួយសហភាពអឺរ៉ុប៖** កិច្ចប្រជុំបានអនុម័តឯកសារចំនួន៣ គឺ (១) ផែនការសកម្មភាពអាស៊ាន-សហភាពអឺរ៉ុបឆ្នាំ២០១៨-២០២២ (២) សេចក្តីប្រកាសអាស៊ាន-សហភាពអឺរ៉ុបស្តីពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស៖ ការប្តេជ្ញាចិត្តជាថ្មីស្តីពីកិច្ចសហប្រតិបត្តិការដើម្បីដោះស្រាយការប្រឈមរួមចំពោះ ការផ្លាស់ប្តូរអាកាសធាតុ និង (៣) សេចក្តីប្រកាសរួមស្តីពីខួបលើកទី៤០នៃទំនាក់ទំនងភាពជាដៃគូសន្ទនាអាស៊ាន-សហភាពអឺរ៉ុបឆ្នាំ២០១៧។

**កិច្ចប្រជុំជាមួយឥណ្ឌា៖** កិច្ចប្រជុំបានទន្ទឹងរង់ចាំការរៀបចំកិច្ចប្រជុំកំពូលរំលឹកខួបអនុស្សាវរីយ៍អាស៊ាន-ឥណ្ឌា ដែលគ្រោងនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៥-២៦ ខែមករា ឆ្នាំ២០១៨ នៅទីក្រុងញូដេលី ប្រទេសឥណ្ឌា និងបានកត់សម្គាល់បញ្ជីសកម្មភាពសម្រាប់ប្រារព្ធខួបអនុស្សាវរីយ៍លើកទី២៥ នៃទំនាក់ទំនងដៃគូសន្ទនា អាស៊ាន-ឥណ្ឌា ឆ្នាំ២០១៧។

**កិច្ចប្រជុំជាមួយសហរដ្ឋអាមេរិក៖** ឯកឧត្តមទេសរដ្ឋមន្ត្រីបានបង្ហាញទស្សនៈថា កិច្ចសហប្រតិបត្តិការអាស៊ាន និងអាមេរិក គួរផ្តោតការយកចិត្តទុកដាក់ឲ្យបានខ្លាំងថែមទៀត លើការអភិវឌ្ឍវិស័យឯកជន ឧត្តមសិក្សា និងវិទ្យាសាស្ត្រ និងបច្ចេកទេស។ ឯកឧត្តមបានស្នើឲ្យមានការគាំទ្ររបស់អាមេរិកចំពោះមជ្ឈមណ្ឌលមីនតំបន់អាស៊ាន (ARMAC)។

កិច្ចប្រជុំបានស្វាគមការតាំងចិត្តរបស់ប្រធានាធិបតី ដូណាល់ ត្រាំ ក្នុងការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ាន និងសហរដ្ឋអាមេរិកលើកទី៥ និងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ដែលនឹងប្រព្រឹត្តទៅនៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ នៅប្រទេសហ្វីលីពីន និងកិច្ចប្រជុំថ្នាក់ដឹកនាំសេដ្ឋកិច្ច របស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិកលើកទី២៥ នៅវៀតណាម។

រដ្ឋមន្ត្រីការបរទេសអាស៊ានបានស្វាគមការចូលរួមរបស់កាណាដា និងសហភាពអឺរ៉ុប ក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ាលើកទី១២ ក្នុងឋានៈជាភ្ញៀវរបស់ប្រធានកិច្ចប្រជុំ និងបានកត់សំគាល់ពីបំណងប្រាថ្នា របស់គេ ក្នុងការចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។

**កិច្ចប្រជុំជាមួយជប៉ុន៖** កិច្ចប្រជុំបានអនុម័តការការកែសម្រួលផែនការអនុវត្តនៃសេចក្តីប្រកាសចក្ខុវិស័យស្តីពីមិត្តភាពនិងកិច្ចសហប្រតិបត្តិការអាស៊ាន-ជប៉ុន៖ ចក្ខុវិស័យរួម អត្តសញ្ញាណរួម និងអនាគតរួម។ នៅក្នុងឱកាសនោះ **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានបញ្ជាក់ថា ឆ្នាំក្រោយគឺជាឆ្នាំខួបអនុស្សាវរីយ៍ ៤៥ឆ្នាំនៃទំនាក់ទំនងអាស៊ាន-ជប៉ុន ហើយ**ឯកឧត្តមទេសរដ្ឋមន្ត្រី**បានសង្កត់ធ្ងន់អំពីសារសំខាន់នៃការលើកកម្ពស់ការតភ្ជាប់រវាងប្រជាជននិងប្រជាជន ដោយផ្តោតជាសំខាន់ទៅលើការផ្លាស់ប្តូរយុវជន និងសហគ្រិនភាព ព្រមទាំងការបន្តគាំទ្ររបស់ជប៉ុនចំពោះការអភិវឌ្ឍធនធានមនុស្សសម្រាប់អាស៊ាន ជាពិសេសសម្រាប់កម្ពុជា ឡាវ មីយ៉ាន់ម៉ារ និងវៀតណាម។

**កិច្ចប្រជុំជាមួយសហព័ន្ធរុស្ស៊ី៖** កិច្ចប្រជុំបានអនុម័តលើចំនួនឯកសារ ៣គឺ៖ (១) សេចក្តីប្រកាសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាននិងរដ្ឋមន្ត្រីការបរទេសសហព័ន្ធរុស្ស៊ីស្តីពីកិច្ចខិតខំរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងភេរវកម្មអន្តរជាតិ (២) ការអនុវត្តផែនទីបង្ហាញផ្លូវនៃបាយការណ៍របស់ក្រុមឥស្សរជនឆ្នើមអាស៊ាន-រុស្ស៊ីនិង (៣) ឯកសារទស្សនទានស្តីពីការបង្កើតបណ្តាញក្រុមអ្នកវិភាគអាស៊ាន-រុស្ស៊ី។

## V. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានបូកបី លើកទី១៨

រដ្ឋមន្ត្រីបានធ្វើការពិភាក្សាលើទិសដៅអនាគតរបស់កិច្ចសហប្រតិបត្តិការអាស៊ានបូកបី និងបានអនុម័តផែនការការងារស្តីពីកិច្ចសហប្រតិបត្តិការអាស៊ានបូកបីឆ្នាំ២០១៨-២០២២។ សម្រាប់ជាទិសដៅអនាគតរបស់អាស៊ានបូកបី **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានផ្តោតលើតួនាទីសំខាន់របស់វិស័យឯកជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម នៅក្នុងការធ្វើកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់។ ក្នុងបរិបទនេះ ឯកឧត្តម

ទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់បំណងរបស់កម្ពុជាក្នុងការចង់ឃើញអំពីការគាំទ្របន្ថែមទៀតរបស់ប្រទេសបូកបីលើការពង្រឹងវិស័យសហគ្រាសធុនតូចនិងមធ្យម ក្នុងសកម្មភាពផលិតកម្ម ការប្រើប្រាស់ឲ្យប្រសើរឡើងផ្នែកបច្ចេកវិទ្យា និងការទទួលបាននូវហិរញ្ញវត្ថុ។

## VI. <u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា លើកទី៧</u>

កិច្ចប្រជុំបានពិភាក្សាលើទិសដៅអនាគតរបស់កិច្ចប្រជុំកំពូលអាស៊ីបូព៌ា និងបានផ្លាស់ប្តូរយោបល់ស្តីពីបញ្ហាតំបន់និងអន្តរជាតិ ដែលជាការព្រួយបារម្ភរួម ដូចជា បញ្ហាសមុទ្រចិនខាងត្បូង ឧបទ្វីបកូរ៉េ និងភេរវកម្ម។

កិច្ចប្រជុំបានអះអាងឡើងវិញពីការតាំងចិត្ត ដើម្បីពង្រឹងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ជាវេទិការបស់ថ្នាក់ដឹកនាំ សម្រាប់កិច្ចសន្ទនា និងសហប្រតិបត្តិការលើបញ្ហាយុទ្ធសាស្ត្រធំទូលាយ នយោបាយ សេដ្ឋកិច្ច និងសង្គម-វប្បធម៌ ដែលជាការព្រួយបារម្ភរួម ក្នុងគោលដៅលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពនៅអាស៊ីបូព៌ា។ កិច្ចប្រជុំបានបញ្ជាក់ជាថ្មីនូវសារសំខាន់នៃតួនាទីស្នូលរបស់អាស៊ាននៅក្នុងដំណើរវិវឌ្ឍន៍នៃនិម្មាបនកម្មតំបន់ និងបានស្វាគមន៍គំនិតផ្តួចផ្តើមរៀបចំផែនការសកម្មភាពទីក្រុងម៉ានីលសម្រាប់វិស័យសហប្រតិបត្តិការនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា ដែលនឹងត្រូវដាក់ជំនួសឲ្យផែនការសកម្មភាពដើម្បីអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងភ្នំពេញស្តីពីគំនិតផ្តួចផ្តើមអភិវឌ្ឍន៍កិច្ចប្រជុំកំពូលអាស៊ីបូព៌ា ឆ្នាំ២០១៥-២០១៧។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានចែករំលែកទស្សនៈស្តីពីបញ្ហាតំបន់និងអន្តរជាតិ ដូចខាងក្រោម៖

ទី១- បញ្ហាសមុទ្រចិនខាងត្បូង៖ ឆ្នាំនេះមានការវិវឌ្ឍល្អទៅមុខ បើធៀបទៅនឹងឆ្នាំកន្លងទៅ។ ខ្ញុំមានសេចក្តីរីករាយដែលអ្នកនៅក្នុងកិច្ចប្រជុំនេះទទួលស្គាល់អំពីការវិវឌ្ឍជាវិជ្ជមាននេះ។ ដោយសារសមិទ្ធផលជាវិជ្ជមានជាច្រើននេះហើយទើបស្ថានការណ៍មានភាពប្រសើរឡើង និងបានបន្ថយភាពតានតឹង។ ចិន និងហ្វីលីពីនបានកប់ទុកការខ្វែងគំនិត និងជ្រើសរើសមធ្យោបាយសន្តិភាពប្រកបដោយគតិបណ្ឌិត ក្នុងការដោះស្រាយជម្លោះ។ កាលពីថ្ងៃទី៦ ខែសីហា ម្សិលមិញ រដ្ឋមន្ត្រីការបរទេសអាស៊ាន និងចិន បានអនុម័តក្របខ័ណ្ឌការងារនៃក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង។ ទម្រង់នៃសេចក្តីប្រកាសរួមរបស់យើងនៅឆ្នាំនេះ ឆ្លុះបញ្ចាំងយ៉ាងល្អនូវនិន្នាការនេះ។ សមិទ្ធផលនេះ គឺកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់ភាគីទាំងអស់ និងការគោរពតាមស្មារតីបាលី-សៀមរាប។ យើងស្វាគមន៍គំនិតផ្តួចផ្តើមបីដំណាក់កាល ដែលស្នើឡើងដោយភាគីចិន ដូចបានលើកឡើងដោយ**ឯកឧត្តម វ៉ាង យី រដ្ឋមន្ត្រីការបរទេសចិន** នៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-ចិន កាលពីម្សិលមិញ។ សមិទ្ធផលជាក់ស្តែងខាងលើនេះ គឺអាចពង្រឹងបាននូវទំនុកចិត្តរបស់យើងក្នុងមាគ៌ា ដើម្បីជានាសន្តិភាព សន្តិសុខ និងវិបុលភាពក្នុងតំបន់របស់យើង។

ទី២- បញ្ហាឧបទ្វីបកូរ៉េ៖ កម្ពុជាបានបង្ហាញនូវការព្រួយបារម្ភលើការកើនឡើងនៃភាពតានតឹងក្នុងឧបទ្វីបរ៉េ ជាពិសេសការបាញ់មីស៊ីលជាបន្តបន្ទាប់ ក៏ដូចជា ការសាកល្បងនូវការបាញ់កាំជ្រួចឆ្លងទ្វីប ដោយសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ដែលជាការបំពានយ៉ាងច្បាស់ទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាជាតិ។ ដូចនេះ កម្ពុជាបានចូលរួមជាមួយប្រទេសសមាជិកអាស៊ាន និង

សហគមន៍អន្តរជាតិ អំពាវនាវឲ្យសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ គោរពយ៉ាងពេញលេញនូវសេចក្តីសម្រេចនានា របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ កម្ពុជាអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់រក្សាភាពអត់ធ្មត់ និងចៀសវាងសកម្មភាពទាំងឡាយណាដែលបង្កឲ្យមានភាពតានតឹងកាន់តែខ្លាំងឡើង។ ក្នុងស្មារតីនេះ កម្ពុជាគាំទ្រគំនិតផ្តួចផ្តើមរួមរបស់រុស្ស៊ី និងចិន ដែលផ្អែកលើសំណើរបស់ចិន ស្តីពី "ការបង្កកទាំងសងខាង" និងការរីកចម្រើនទៅមុខទាំងសងខាងស្របគ្នាឆ្ពោះទៅរកការបំបាត់អាវុធនុយក្លេអ៊ែរនៅឧបទ្វីបកូរ៉េ និងសំណើរបស់រុស្ស៊ី ស្តីពី "គម្រោងដោះស្រាយបញ្ហាកូរ៉េតាមដំណាក់កាល" ដើម្បីចូលរួមបន្ថយភាពតានតឹង និងជំរុញការជឿជាក់ និងការកសាងទំនុកចិត្តនៅក្នុងតំបន់។ ទន្ទឹមនឹងនេះ យើងស្វាគមន៍សំណើរបស់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ ក្នុងការផ្តើមកិច្ចសន្ទនាជាមួយសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េឡើងវិញ ដើម្បីបន្ធូរបន្ថយភាពតានតឹង និង ការប្រឈមមុខដាក់គ្នា។

## VII. <u>កិច្ចប្រជុំវេទិកាតំបន់អាស៊ានលើកទី ២៤</u>

កិច្ចប្រជុំបានចេញផ្សាយនូវទស្សនវិស័យសន្តិសុខនៃវេទិកាតំបន់អាស៊ានប្រចាំឆ្នាំ២០១៧ និងបានអនុម័ត៖

១. បញ្ជីសកម្មភាព Track I នៃវេទិកាតំបន់អាស៊ានសម្រាប់ឆ្នាំ២០១៧-២០១៨

២. សេចក្តីប្រកាសវេទិកាតំបន់អាស៊ានស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការដោះស្រាយ និងប្រយុទ្ធប្រឆាំងគ្រឿងញៀន

៣. សេចក្តីប្រកាសវេទិកាតំបន់អាស៊ានស្តីពីកិច្ចសហប្រតិបត្តិការបង្ការ និងការលុបបំបាត់ការនេសាទខុសច្បាប់ មិនរាយការណ៍ និងមិនមានវិធានត្រឹមត្រូវ ក្នុងការនេសាទ និង

៤. បញ្ជីសកម្មភាព Track I នៃវេទិកាតំបន់អាស៊ានសម្រាប់ឆ្នាំ២០១៧-២០១៨ ឯកសារទស្សនាទានស្តីពីការបង្កើតអន្តរសម័យប្រជុំនៃវេទិកាតំបន់អាស៊ាន ស្តីពីសន្តិសុខក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍។

## VIII. <u>កិច្ចប្រជុំមេគង្គ</u>

### ១) <u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃគំនិតផ្តួចផ្តើមមេគង្គក្រោមលើកទី១០</u>

កិច្ចប្រជុំគំនិតផ្តួចផ្តើមមេគង្គក្រោមលើកទី១០ បានអនុម័តសេចក្តីប្រកាសរួម ដែលបានអបអរ ដល់ការវិវឌ្ឍនៃការអនុវត្តផែនការសកម្មភាពគំនិតផ្តួចផ្តើមមេគង្គក្រោមឆ្នាំ២០១៦-២០២០ ក្រោមសសរស្តម្ភ៦ និងបានស្វាគមគំនិតផ្តួចផ្តើមទិន្នន័យគ្រប់គ្រងទឹករបស់អាមេរិក ដែលមានគោលបំណងអភិវឌ្ឍវេទិកាបែងចែកទិន្នន័យតំបន់ ដើម្បីអាចធ្វើការសម្រេចចិត្តបានប្រសើរឡើងស្តីពីការអភិវឌ្ឍ និងការគ្រប់គ្រងទន្លេ។ កិច្ចប្រជុំក៏បានស្វាគមន៍ការបន្តការតាំងចិត្តរបស់រដ្ឋបាលអាមេរិកថ្មី ចំពោះកិច្ចសហប្រតិបត្តិការគំនិតផ្តួចផ្តើមមេគង្គក្រោម។

### ២) <u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១០</u>

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១០ បានអនុម័តសេចក្តីប្រកាសរួមរបស់ប្រធាន ដែលបានពិនិត្យឡើងវិញពីការវិវឌ្ឍកិច្ចសហប្រតិបត្តិការជាទៀងទាត់ ក្រោមគំនិតផ្តួចផ្តើមការតភ្ជាប់មេគង្គ-ជប៉ុន។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានលើកឡើងពីសារសំខាន់នៃការតភ្ជាប់រវាងហេដ្ឋារចនាសម្ព័ន្ធទន់ និងរឹង និងបានស្នើឲ្យមានការបង្កើនភាពជាដៃគូរវាងវិស័យឯកជន-សាធារណៈ និងពិចារណាលើហិរញ្ញប្បទានសម្បទានសម្រាប់ប្រទេសមេគង្គ ដើម្បីលើកកម្ពស់គុណភាពហេដ្ឋារចនាសម្ព័ន្ធ។

៣) <u>កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-គង្គាលើកទី៨</u>

កិច្ចប្រជុំមេគង្គ-គង្គាលើកទី៨ បានអនុម័តសេចក្តីប្រកាសរួមរបស់រដ្ឋមន្ត្រី ដែលបានពិនិត្យឡើងវិញនូវវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៦-២០១៨ ក្នុងវិស័យទេសចរណ៍ វប្បធម៌ អប់រំ ដឹកជញ្ជូន និងទំនាក់ទំនង និងបានកត់សម្គាល់ពីការវិវឌ្ឍដែលសម្រេចបាន ចំពោះការរៀបចំផែនការមេសម្រាប់តំបន់មេគង្គ-គង្គា។

កម្ពុជាបានសង្ខេបជូនកិច្ចប្រជុំអំពីកិច្ចប្រឹងប្រែងរបស់កម្ពុជាក្នុងការធានានូវស្ថិរភាព និងប្រតិបត្តិការសារមន្ទីរវាយនភណ្ឌ នៅទីក្រុងសៀមរាប និងបានស្នើដល់ប្រទេសសមាជិកផ្តល់នូវសម្ភារថ្មីទៀត សម្រាប់ការដាក់តាំង និងបង្កើនយន្តការសម្របសម្រួល ក្នុងការគាំទ្រដល់ដំណើរការរបស់សារមន្ទី។

## IX. <u>កិច្ចប្រជុំទ្វេភាគី</u>

ក្នុងអំឡុងពេលចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៥០ **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** ក៏មានជំនួបទ្វេភាគីដោយឡែកពីគ្នា ជាមួយឯកឧត្តម Mevlut Cavusoglu រដ្ឋមន្ត្រីការបរទេសទួរគី ឯកឧត្តម Vasantha Senanayake អនុរដ្ឋមន្ត្រីការបរទេសស្រីលង្កា ឯកឧត្តម Wang Yi រដ្ឋមន្ត្រីការបរទេសចិន និងលោកជំទាវ Kang Kyung-wha រដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ។ នៅក្នុងជំនួបទ្វេភាគីនេះ ការពិភាក្សា និងការផ្លាស់ប្តូរទស្សនៈ ផ្តោតទៅលើទំនាក់ទំនងទ្វេភាគី និងបញ្ហាតំបន់ និងអន្តរជាតិផ្សេងទៀត។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** និងឯកឧត្តមរដ្ឋមន្ត្រីការបរទេសទួរគី បានពិភាក្សាពីការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី រួមទាំងសំណើរបស់នាយករដ្ឋមន្ត្រីទួរគីគោរពអញ្ជើញសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅធ្វើទស្សនកិច្ចនៅប្រទេសទួរគីក្នុងឆ្នាំ២០១៧នេះ។ រដ្ឋមន្ត្រីការបរទេសទួរគីក៏បានអញ្ជើញឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន ទៅធ្វើទស្សនកិច្ចនៅប្រទេសទួរគី នៅឆ្នាំក្រោយ។ កិច្ចជំនួបនេះបានពិភាក្សាអំពីការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសេដ្ឋកិច្ចរួមលើកទី២ និងកិច្ចប្រជុំការពិគ្រោះយោបល់លើកទី៣ ការបង្កើតឲ្យមានជើងហោះហើរត្រង់ និងជំនួយពីប្រទេសទួរគីលើការបោសសម្អាតមីននៅកម្ពុជា និងមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន។ រដ្ឋមន្ត្រីការបរទេសទួរគីបានថ្លែងអំណរគុណដល់កម្ពុជា ដែលបានគាំទ្រការស្នើសុំរបស់ទួរគីចូលជាដៃគូសន្ទនាតាមវិស័យរបស់អាស៊ាន។

អនុរដ្ឋមន្ត្រីការបរទេសស្រីលង្កា បានស្នើកម្ពុជាឲ្យគាំទ្រប្រទេសស្រីលង្កាក្លាយជាដៃគូសន្ទនាតាមវិស័យរបស់អាស៊ាន ហើយ**ឯកឧត្តមទេសរដ្ឋមន្ត្រី**បានជម្រាបជូនអំពីបែបបទដើម្បីទទួលបានឋានៈនេះ។

កិច្ចប្រជុំជាមួយរដ្ឋមន្ត្រីការបរទេសចិនបានផ្តោតលើការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី។ ភាគីទាំងពីរបានពិភាក្សាពីដំណើរទស្សនកិច្ចទៅចិនរបស់**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** នាពេលខាងមុខ និងការអញ្ជើញ**នាយករដ្ឋមន្ត្រីចិន ឯកឧត្តម លី ខឺឈាង** មកបំពេញទស្សនកិច្ចនៅកម្ពុជា។ រដ្ឋមន្ត្រីការបរទេសចិន។ រដ្ឋមន្ត្រីការបរទេសចិនក៏បានអញ្ជើញឯកឧត្តមទេសរដ្ឋមន្ត្រីទៅបំពេញទស្សនកិច្ចនៅចិនផងដែរ។

ភាគីទាំងពីរក៏បានពិភាក្សាអំពីការជំរុញកិច្ចសហប្រតិបត្តិការមេគង្គរវាងតំបន់មេគង្គនិងចិន និងរវាងចិននិងអាស៊ាន និងបានផ្លាស់ប្តូរទស្សនៈពីបញ្ហាតំបន់ និងអន្តរជាតិ។

កិច្ចប្រជុំជាមួយរដ្ឋមន្ត្រីការបរទេសសាធារណរដ្ឋកូរ៉េ ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី និងការសម្របសម្រួលសម្រាប់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-កូរ៉េ ដែលរដ្ឋមន្ត្រីការបរទេសទាំងពីរនឹងត្រូវធ្វើជាសហប្រធាននៃកិច្ចប្រជុំ។ រដ្ឋមន្ត្រីទាំងពីរបានផ្លាស់ប្តូរទស្សនៈស្តីពីបញ្ហាឧបទ្វីបកូរ៉េ ព្រមទាំងបញ្ហាតំបន់និងអន្តរជាតិមួយចំនួនដែលជាក្តីបារម្ភរួម។

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែសីហា ឆ្នាំ២០១៧